អ៊ុង ហួត ហ៊ុន សែន

# អនុក្រឹត្យ លេខ ៥៣ អនក្រ.បក

## ស្ដីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ សំរាប់ទិញឧបករណ៍ DVOR/DMG បំពាក់អោយអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១០៩៤/៩៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ១៩៩៤ និងលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ១៩៩៧ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ ១១ នស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញសេចក្ដីប្រកាសរបស់រាជរដ្ឋាភិបាល លេខ ០១សប្រក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៤ ស្ដីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្ដីពីបែបបទឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- តាមសំណើរបស់ឯកឧត្ដមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

មាត្រា ១.- អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រើប្រាស់គណនី ឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈ ដែលត្រូវបានបង្កើតឡើងតាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ ដើម្បីទិញឧបករណ៍ DVOR/DMG បំពាក់អោយ អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ដើម្បីធានាការហោះហើរឡើងវិញ និងបំរើ អោយនយោបាយបើកចំហរជើងមេឃក្នុងវិស័យអាកាសចរជូនរដ្ឋលេខាធិការដ្ឋានអាកាស ចរស៊ីវិល មានទឹកប្រាក់ ៣.១៨៨.៩៩២ $US (បីលានមួយរយប៉ែតសិបប្រាំបីពាន់ ប្រាំបួនរយកៅសិបពីរដុល្លារអាមេរិក) ។

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៧

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខានិងត្រា |
| **អ៊ុង ហួត** | **ហ៊ុន សែន** |

* * *

**អនុក្រឹត្យ លេខ ៥៤ អនក្រ.បក**

**ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ**

**របស់ក្រសួងពាណិជ្ជកម្ម**

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា